**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ១៤៩ អនក្រ.បក

## អនុក្រឹត្យ

### ស្តីពី

### ការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិរបស់រដ្ឋនូវទីតាំងដីសម្រាប់សាងសង់អគារទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ ស្ថិតក្នុងខេត្តព្រៃវែង

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារព្រំដែនសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានកំណត់ផ្ទៃដីសម្រាប់ធ្វើការសាងសង់អគារទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិ ម៉ឺនជ័យ ដែលមានទីតាំងស្ថិតនៅក្នុងភូមិត្បូងវត្ត ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។

**មាត្រា ២.-**

ត្រូវបានធ្វើចំណាត់ថ្នាក់បរិវេណដីដូចមានបញ្ជាក់ក្នុងប្លង់ឧបសម្ព័ន្ធ ដែលមានផ្ទៃក្រឡាសរុបប្រមាណ ៨០.១៩២ម៉ែត្រការ៉េ ជាប្រភេទដីដែលមានលក្ខណសម្បត្តិជាទ្រព្យសាធារណៈរបស់រដ្ឋប្រកបដោយរបបគតិយុត្ត ដែលមានទីតាំងស្ថិតនៅក្នុងភូមិត្បូងវត្ត ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ស្របតាមមាត្រា១៥ មាត្រា១៦ មាត្រា១៧ នៃច្បាប់ភូមិបាល ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ និងមាននិយាមកាដូចខាងក្រោម៖

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| A- | 587999.492 | 1282530.219 | L- | 588306.1059 | 1282328.671 |
| B- | 588091.8558 | 1282503.265 | M- | 588221.9756 | 1282201.217 |
| C- | 588121.8719 | 1282489.17 | N- | 588216.4487 | 1282142.263 |
| D- | 588123.7772 | 1282443.759 | O- | 588220.2719 | 1282128.882 |
| E- | 588135.8271 | 1282412.703 | P- | 588077.0783 | 1282154.397 |
| F- | 588135.6086 | 1282403.331 | Q- | 588031.5439 | 1282177.519 |
| G- | 588242.2903 | 1282365.851 | R- | 587989.2536 | 1282323.293 |
| H- | 588276.3961 | 1282364.227 | S- | 587977.992 | 1282379.954 |
| I- | 588333.7373 | 1282389.675 | T- | 587978.5267 | 1282399.948 |
| J- | 588363.731 | 1282366.943 | U- | 587979.2137 | 1282436.92 |
| K- | 588363.0372 | 1282352.47 | | | |

**មាត្រា ៣.-**

ត្រូវបានហាមឃាត់នូវរាល់សកម្មភាពទន្ទ្រានកាន់កាប់ ដោះដូរ ទិញលក់ ផ្ទេរកម្មសិទ្ធិ ឬផ្ទេរសិទ្ធិកាន់កាប់ដី ការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ការចេញលិខិតអនុញ្ញាតឱ្យសាងសង់ថ្មីនៅក្នុងបរិវេណដីដូចបានកំណត់ក្នុងមាត្រា២នៃអនុក្រឹត្យនេះ លើកលែងតែការផ្ទេរកម្មសិទ្ធិសម្រាប់បម្រើផលប្រយោជន៍សាធារណៈ។

រាល់ការបំពានលើបទប្បញ្ញត្តិដូចមានចែងខាងលើ អ្នកប្រព្រឹត្តបទល្មើសត្រូវទទួលទណ្ឌកម្មដូចដែលមានចែងនៅក្នុងច្បាប់ភូមិបាល ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។

**មាត្រា ៤.-**

ម្ចាស់កម្មសិទ្ធិ ឬភោគីនៃដីស្ថិតក្នុងបរិវេណដីខាងលើត្រូវផ្ទេរកម្មសិទ្ធិប្រគល់ជូនរដ្ឋ ដើម្បីជាប្រយោជន៍សាធារណៈ ដោយទទួលបាននូវការទូទាត់សំណងពីគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់គម្រោងសាងសង់អគារទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ ស្របតាមច្បាប់ស្តីពីអស្សាមិករណ៍ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៩ រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ...អនក្រ.បក ចុះថ្ងៃ......ខែ......
ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី...១២...... ខែ...វិច្ឆិកា...ឆ្នាំ ២០១៨

# ផែនទីបង្ហាញទីតាំងដីស្នើសុំបន្តក

បម្រុងទុកសំរាប់សាងសង់ទីស្នាក់ការ និង ស្ថានីយ៍ត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិម៉ុនជ័យ
ស្ថិតនៅភូមិ ត្បូងត្រ ឃុំត្រពាំងប្រិយ ស្រុកកំចាយមារ ខេត្តព្រៃវែង

- យោងស្មារតីកិច្ចប្រជុំគណៈអភិបាលខេត្ត និង ក្រុមការងារថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ ។




ទំហំ: 80192 $m^2$

| Projected Coordinate System: | | |
|---|---|---|
| WGS_1984_UTM_Zone_48N | | |
| ID | X | Y |
| A | 587999.492 | 1282530.219 |
| B | 588091.8558 | 1282503.265 |
| C | 588121.8719 | 1282489.17 |
| D | 588123.7772 | 1282443.759 |
| E | 588135.8271 | 1282412.703 |
| F | 588135.6086 | 1282403.331 |
| G | 588242.2903 | 1282365.851 |
| H | 588276.3961 | 1282364.227 |
| I | 588333.7373 | 1282389.675 |
| J | 588363.731 | 1282366.943 |
| K | 588363.0372 | 1282352.47 |
| L | 588306.1059 | 1282328.671 |
| M | 588221.9756 | 1282201.217 |
| N | 588216.4487 | 1282142.263 |
| O | 588220.2719 | 1282128.882 |
| P | 588077.0783 | 1282154.397 |
| Q | 588031.5439 | 1282177.519 |
| R | 587989.2536 | 1282323.293 |
| S | 587977.992 | 1282379.954 |
| T | 587978.5267 | 1282399.948 |
| U | 587979.2137 | 1282436.92 |

**បានឃើញ និង ឯកភាព**
ថ្ងៃ......ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ព្រៃវែង ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៨
**អភិបាលខេត្តព្រៃវែង**
ជា_សុមេធី

**បានពិនិត្យត្រឹមត្រូវ**
ថ្ងៃ......ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ព្រៃវែង ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៨
**ប្រធានមន្ទីរ ដ.ន.ស.ស**
អេង_ផេងឡេង

ថ្ងៃទី២៤.ខែ.កក្កដា.ឆ្នាំ២០១៨
**ទាស់ខែង និង គូអជាយ**
- លោក ពៅ វណ្ណា
- លោក រឿន រ៉ារីណៃ